**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**សាលាភូមិន្ទរដ្ឋបាល**

*រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១២*

# របាយការណ៍
# ស្តីពី
# ទស្សនទានសំខាន់ៗស្តីពីវិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា

កាលព្រឹកថ្ងៃទី១៩ និង២២ ខែមិថុនា ឆ្នាំ២០១២ ឯកឧត្តម ព្រុំ សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានធ្វើបទបង្ហាញ ជូនដល់សិស្សនិងកម្មសិក្សាការីនៃសាលាភូមិន្ទរដ្ឋបាល ដោយផ្តោតទៅលើចំណុចចម្បងចំនួន០៤ គឺ(១) ទស្សនទានសំខាន់ៗពាក់ព័ន្ធទៅវិមជ្ឈការ និងវិសហមជ្ឈការ (២) វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា និង(៣) ច្បាប់រៀបចំអង្គការសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និង(៤) បញ្ហាប្រឈម និងសេចក្តីសន្និដ្ឋាន។

ហេតុអ្វីបានជាកម្ពុជាឆាប់អនុវត្តនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ពីព្រោះតាមបទពិសោធន៍បរទេស គេប្រើរយៈពេលប្រមាណពី៦០ ទៅ១០០ឆ្នាំ?

- ការអនុវត្តនយោបាយកែទម្រង់រដ្ឋបាលសាធារណៈ តាមរយៈ D&D ដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ
- ក្រោយសង្គ្រាមត្រជាក់ ពិភពលោកបានប្តូរពីសេដ្ឋកិច្ចផែនការមកជាសេដ្ឋកិច្ចទីផ្សារ។ សេដ្ឋកិច្ចទីផ្សារ មានន័យថា ជាការធ្វើវិមជ្ឈការទីផ្សារ (Decentralized Market)។ កម្ពុជា បានអនុវត្តនយោបាយកែទម្រង់ដីធ្លី បង្កើតឲ្យមានរបបកម្មសិទ្ធិលើដីធ្លី និងប្រកាន់យករបបសេដ្ឋកិច្ចទីផ្សារតាំងពីឆ្នាំ ១៩៨៩។ ដូចនេះ វិមជ្ឈការ និងវិសហមជ្ឈការមិនមែនជារឿងថ្មីនៅកម្ពុជានោះទេ ហើយការអនុវត្តប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការក៏មិនមែនចម្លងពីបរទេស ឬផ្គាប់ចិត្តអ្នកណាម្នាក់នោះដែរ គឺមិនមែនកម្ពុជានាំផលិតផលពីខាងក្រៅទេ ប៉ុន្តែក៏ពឹងផ្អែកទៅលើបទពិសោធន៍ពីខាងក្រៅដែរ ដោយគូសវាសនយោបាយនេះឲ្យស្របទៅនឹងបរិបទ និងស្ថានភាពជាក់ស្តែងរបស់កម្ពុជា។

ដូចនេះ គោលបំណងជារួមនៃការអនុវត្តនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា គឺដើម្បីបង្វិតជិតរដ្ឋបាលសាធារណៈឲ្យនៅក្បែរប្រជាពលរដ្ឋ ដើម្បីអភិវឌ្ឍ និងពង្រឹងលទ្ធិប្រជាធិបតេយ្យមូលដ្ឋាន និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

## ១. ទស្សនទានសំខាន់ៗពាក់ព័ន្ធទៅវិមជ្ឈការ និងវិសហមជ្ឈការ

ទស្សនទានសំខាន់ៗដែលពាក់ព័ន្ធ រួមមាន៖ វិមជ្ឈការ(Decentralization) វិសហមជ្ឈការ (Deconcentration) ការធ្វើប្រតិភូកម្ម (Delegation) សាប់ស៊ីឌីយ៉ារីធី (Subsidiarity) ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (Democratic Development) និងការអភិវឌ្ឍផ្នែករដ្ឋបាល និងផ្នែកនយោបាយ (Administrative and Political Development)។

### ក. វិមជ្ឈការ

**និយមន័យ៖** វិមជ្ឈការសំដៅលើការប្រគល់ភាពជាម្ចាស់ឲ្យទៅក្រុមប្រឹក្សាជាប់ឆ្នោតនៅថ្នាក់ក្រោមជាតិ។ មានន័យថា រាជរដ្ឋាភិបាលប្រគល់ឲ្យក្រុមប្រឹក្សានូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និងធនធាន ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់មូលដ្ឋាន។ ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋមូលដ្ឋានលើបញ្ហាទាំងនោះ។

លក្ខណៈសម្គាល់របស់វិមជ្ឈការ មានៈ

- ក្រុមប្រឹក្សាជាប់ឆ្នោត
- រាជរដ្ឋាភិបាលផ្ទេរភាពជាម្ចាស់លើមុខងារ
- ស្វ័យភាពនៅមូលដ្ឋាន និងគណនេយ្យភាព
- កិច្ចសហការគ្នា និងការពឹងផ្អែកគ្នាទៅវិញទៅមក។

**ខ. វិសហមជ្ឈការ**

**និយមន័យៈ** វិសហមជ្ឈការ គឺជាយន្តការមួយដែលរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន ធ្វើប្រតិភូកម្មមុខងារ សិទ្ធិ អំណាច និងធនធានទៅអង្គភាពក្រោមបង្គាប់ ឬទៅក្រុមប្រឹក្សាប្រភេទណាមួយ ដើម្បីអនុវត្តក្នុងនាមរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន ។ អង្គភាព ឬក្រុមប្រឹក្សានោះ ត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នស្របទៅតាមតម្រូវការនៃការធ្វើប្រតិភូកម្មនោះ។

លក្ខណៈសម្គាល់របស់វិសហមជ្ឈការ មានៈ

- ថ្នាក់ជាតិរក្សាភាពជាម្ចាស់
- គណនេយ្យភាពពីថ្នាក់ក្រោមឡើងលើ។

*ភាពខុសគ្នារវាងវិមជ្ឈការ និងវិសហមជ្ឈការ គឺភាពជាម្ចាស់* ។ វិមជ្ឈការមានភាពជាម្ចាស់ រីឯវិសហមជ្ឈការ គ្មានភាពជាម្ចាស់ទេគឺធ្វើអ្វីៗតំណាងឲ្យអាជ្ញាធរថ្នាក់លើដែលធ្វើប្រតិភូកម្ម។ ការងារបែបវិសហមជ្ឈការ មានដូចជា ការងារធ្វើបញ្ជីអត្រានុកូលដ្ឋាន (សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្រមរណភាព) ជាសមត្ថកិច្ចរបស់ឃុំ/សង្កាត់ ដែលការងារនេះធ្វើឡើងក្នុងនាមក្រសួងមហាផ្ទៃ ការងារចុះបញ្ជីបោះឆ្នោត ជាសមត្ថកិច្ចរបស់ឃុំ/សង្កាត់ ដែលធ្វើឡើងក្នុងនាមគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ចំណែកឯ ភាពជាម្ចាស់ គឺជាអំណាចពេញលេញដែលរដ្ឋបាលវិមជ្ឈការមានសិទ្ធិក្នុងការបំពេញការងារក្នុងនាមខ្លួនឯងផ្ទាល់។ អំណាច សំដៅទៅលើមុខងារ បុគ្គលិក និងហិរញ្ញវត្ថុ។ ប៉ុន្តែទាំងវិមជ្ឈការ ទាំងវិសហមជ្ឈការ គឺជាមធ្យោបាយដើម្បីសម្រេចបាននូវគោលដៅរបស់រដ្ឋ ដែលចាំបាច់ត្រូវកំណត់អំពីវិសាលភាព ធនធាន និងមុខងារឲ្យបានច្បាស់លាស់។

**គ. ប្រតិភូកម្ម**

ប្រតិភូកម្ម គឺជាការផ្ទេរមុខងារ ការទទួលខុសត្រូវ អំណាច និងឆន្ទានុសិទ្ធិ ដើម្បីគ្រប់គ្រង និងអនុវត្តមុខងារក្នុងនាមអាជ្ញាធរដែលធ្វើប្រតិភូកម្ម ដោយផ្អែកតាមតម្រូវការនៃការធ្វើប្រតិភូកម្មនោះ។ អាជ្ញាធរដែលបានធ្វើប្រតិភូកម្ម នៅតែរក្សាភាពជាម្ចាស់លើកិច្ចការដែលបានធ្វើប្រតិភូកម្ម។ ការធ្វើប្រតិភូកម្ម តែងមានសេចក្តីណែនាំ និងការត្រួតពិនិត្យយ៉ាងល្អិតល្អន់។

**ឃ. សាប់ស៊ីឌីយ៉ារីធី**

គឺជាប្រភេទការងារដែលថ្នាក់ក្រោមអាចធ្វើបាន។ មានន័យថា រដ្ឋបាលថ្នាក់ជាតិ ត្រូវប្រគល់ការងារណាដែលថ្នាក់ក្រោមជាតិអាចធ្វើបាន គឺប្រដូចទៅនឹងការយកកញ្ច្រែងមករែងដី ដីដែលធំជាការងាររបស់រដ្ឋបាលថ្នាក់ជាតិ ដីដែលធំល្មមជាការងាររបស់ថ្នាក់រាជធានី/ខេត្ត រហូតដល់ដីដែលតូចៗជាការងាររបស់ឃុំ/សង្កាត់។ ជារួមមក រដ្ឋមានតួនាទីធ្វើបញ្ជីមុខងារឲ្យបានច្បាស់លាស់ដើម្បីកំណត់ប្រភេទនៃមុខងារណាខ្លះដែលរដ្ឋបាលថ្នាក់ក្រោមជាតិអាចធ្វើបាន ក្នុងគោលដៅនៃការស្វែងរកឧត្តមភាពប្រៀបធៀប។

ចំណាំៈ ពាក្យស្វ័យភាពមិនមែនជាអធិបតេយ្យភាពទេ។ ដូចប្រសាសន៍របស់សម្តេចតេជោ "ហាមបង្កើតរដ្ឋនៅក្នុងរដ្ឋ"។ ថ្មីៗនេះ មានករណីបង្កើតតំបន់អប្បគមន៍នៅក្នុងស្រុកក្បាលដំរី ខេត្តក្រចេះ ដែលទង្វើនេះមិនមែនជាស្វ័យភាពក្នុងប្រព័ន្ធវិមជ្ឈការនោះទេ។

## ២. វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា

ទាក់ទងទៅនឹងវិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា គឺផ្តោតទៅលើ០៣ចំណុចដូចតទៅ៖ (ក)គោលដៅចម្បង នៃវិមជ្ឈការ និងវិសហមជ្ឈការ (ខ) សមិទ្ធផលរបស់វិមជ្ឈការ និងវិសហមជ្ឈការចាប់ពីឆ្នាំ២០០២ និង (គ) ការពង្រីក វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិទាំងមូល។

**ក. គោលដៅចម្បងនៃវិមជ្ឈការ និងវិសហមជ្ឈការ**

វិមជ្ឈការ និងវិសហមជ្ឈការ មានគោលដៅចម្បង ដូចខាងក្រោម៖

- លទ្ធិប្រជាធិបតេយ្យនិងការអភិវឌ្ឍ (តម្លៃស្នូលនៃការស្ថាបនាជាតិដែលកំណត់នៅក្នុងរដ្ឋធម្មនុញ្ញរបស់កម្ពុជា)
- បង្កើត ជំរុញ និងធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
- ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ដែលរួមមាន ការអភិវឌ្ឍផ្នែករដ្ឋបាល ឬមូលធនសង្គម និងការអភិវឌ្ឍផ្នែកនយោបាយ ឬមូលធននយោបាយ

**ការអភិវឌ្ឍផ្នែករដ្ឋបាល៖** ទាក់ទងទៅនឹងការផ្តល់សេវា មធ្យោបាយ និងហេដ្ឋារចនាសម្ព័ន្ធពិតប្រាកដ ដោយអាជ្ញាធរ អភិបាលកិច្ច តាមរយៈរដ្ឋបាលប្រកបដោយសច្ចធម៌ មានតម្លាភាព មានគណនេយ្យភាព និងមានសមត្ថភាព។

**ការអភិវឌ្ឍផ្នែកនយោបាយ៖** ទាមទារឲ្យមានការបង្កើតក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិដែលមានស្វ័យភាព (ប៉ុន្តែមិនមែនជាអធិបតេយ្យភាព) តាមរយៈការជ្រើសរើសដោយផ្ទាល់ ឬដោយប្រយោល។ ការអភិវឌ្ឍផ្នែកនយោបាយនេះ ជាការអភិវឌ្ឍផ្នែកគំនិត និងចំណេះដឹងនៃការដឹកនាំ ដើម្បីធានាឲ្យមានចីរភាពនៃការអភិវឌ្ឍ។

**ខ. សមិទ្ធផលរបស់វិមជ្ឈការ និងវិសហមជ្ឈការចាប់ពីឆ្នាំ២០០២**

ចាប់តាំងពីឆ្នាំ២០០២ មក កម្ពុជាបានបង្កើតសមិទ្ធផលជាច្រើនពីការអនុវត្តប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ។ សមិទ្ធផលសំខាន់ៗទាំងនោះ មានដូចខាងក្រោម៖

- ស្ថាប័នអភិបាលកិច្ចមូលដ្ឋាន (មានក្រុមប្រឹក្សាឃុំ/សង្កាត់ ចំនួន១៦៣៣) និងយន្តការចាំបាច់នានាសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ដែលរួមមាន ភាពជាតំណាងសាធារណៈ ការពិគ្រោះយោបល់ និងការចូលរួម ការឆ្លើយតប និងគណនេយ្យភាព
- ការកសាង និងអភិវឌ្ឍសមត្ថភាព ដែលក្នុងនោះមន្ត្រីថ្នាក់ជាតិ និងក្រោមជាតិ ចំនួនប្រមាណជាង ៦០.០០០ នាក់ បានទទួលការបណ្តុះបណ្តាល
- ការកសាងហេដ្ឋារចនាសម្ព័ន្ធ គឺ ហេដ្ឋារចនាសម្ព័ន្ធសង្គមតូច និងមធ្យមជាច្រើនត្រូវបានបង្កើតឡើងនៅមូលដ្ឋានដើម្បីលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋ ដូចជា ផ្លូវ ស្ពាន អណ្តូងទឹក
- ធនធានហិរញ្ញវត្ថុ ដែលចាប់តាំងពីឆ្នាំ២០០២ ដល់ឆ្នាំ២០១០ រាជរដ្ឋាភិបាលបានវិភាជថវិកាជាតិប្រមាណជាង១៦៦លានដុល្លារ និងការចូលរួមពីដៃគូអភិវឌ្ឍនានាចំនួនជាង ៣០០លានដុល្លារ។

**គ. ការពង្រីក វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិទាំងមូល**

ផ្អែកលើយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងមេរៀនពិសោធន៍នៃការអនុវត្តវិមជ្ឈការ និងវិសហមជ្ឈការកន្លងមក កម្ពុជាបានសម្រេចការងារសំខាន់ៗក្នុងការពង្រីកវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ដូចខាងក្រោម៖

- ក្របខ័ណ្ឌយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ឆ្នាំ២០០៥
- ច្បាប់រៀបចំអង្គការ ឆ្នាំ២០០៨ ដែលសំដៅទៅលើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានក្រុមប្រឹក្សារាជធានី ខេត្ត ចំនួន២៤ និងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ចំនួន ១៩៣ ត្រូវបានបោះឆ្នោតជ្រើសរើសជាអសកលដោយក្រុមប្រឹក្សាឃុំ/សង្កាត់
- ការកសាងបទដ្ឋានគតិយុត្តសម្រាប់គាំទ្រដំណើរការកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ

- កម្មវិធីជាតិ១០ឆ្នាំ ត្រូវបានអនុម័តដោយរាជរដ្ឋាភិបាល
- ការកសាង និងអភិវឌ្ឍសមត្ថភាពមន្ត្រីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា នៅតែបន្តបណ្ដុះបណ្ដាលជាបន្តបន្ទាប់។

## ៣. ច្បាប់រៀបចំអង្គការសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ

ចំណុចចម្បងដែលលើកឡើងនៅក្នុងផ្នែកនេះ រួមមាន៖ (ក) គោលបំណងរបស់ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ខ) រចនាសម្ព័ន្ធ និងតួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (គ) មុខងារ បុគ្គលិក និងធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និង(៤) គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)។

**ក. គោលបំណងរបស់ច្បាប់រៀបចំអង្គការ**

ច្បាប់អង្គការមានគោលបំណងធំៗចំនួនបី គឺ (ក១) ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ក២) ការកែសម្រួលព្រំប្រទល់ ឈ្មោះរដ្ឋបាលថ្នាក់ក្រោមជាតិ និង(ក៣) នីតិបុគ្គល។

**ក១. ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

ច្បាប់រៀបចំអង្គការមានគោលបំណងធ្វើឲ្យការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្លាយជារដ្ឋបាលឯកភាព បង្កើត ជំរុញ និងធ្វើឲ្យមានចីរភាពក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងការអនុវត្តនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

**រដ្ឋបាលឯកភាព** ជារដ្ឋបាលមួយដែល៖

- អាចម្ចាស់ការក្នុងការគ្រប់គ្រង ចាត់ចែងមុខងារ និងធនធាន រាប់ទាំងហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា
- មានសមត្ថភាពសម្របសម្រួលប្រកបដោយប្រសិទ្ធភាពជាមួយមន្ទីរអង្គភាពនានារបស់រាជរដ្ឋាភិបាល ដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្នុងការផ្ដល់សេវាកម្ម និងការអភិវឌ្ឍផ្សេងៗទៀត។

និយាយឲ្យស្រួលយល់ រដ្ឋបាលឯកភាព គឺជារដ្ឋបាលដែលដើរតួនាទីក្នុងការសម្របសម្រួលឲ្យមានភាពស៊ីសង្វាក់គ្នា រវាងខ្សែបណ្ដោយ និងខ្សែទទឹង ដែលក្នុងនោះមានរដ្ឋបាលថ្នាក់ខេត្តជាតំណាងឲ្យរាជរដ្ឋាភិបាលលើគ្រប់វិស័យក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ជាតួអង្គជំរុញឲ្យមន្ទីជំនាញនានាមានសង្គតិភាពរដ្ឋបាលជាមួយគ្នា។ ឧទាហរណ៍ ការធ្វើផែនការអភិវឌ្ឍ និងថវិការបស់ក្រុមប្រឹក្សា/រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវតែមានការធ្វើសមាហរណកម្មឲ្យមានភាពស៊ីសង្វាក់គ្នា។ រដ្ឋបាលឯកភាពតំណាងឲ្យក្រុមប្រឹក្សា។

**បង្កើត ជំរុញ និងធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ** គឺសំដៅដល់ការអភិវឌ្ឍផ្នែករដ្ឋបាល ឬមូលធនសង្គម និងការអភិវឌ្ឍផ្នែកនយោបាយ ឬមូលធននយោបាយ ដូចដែលបានលើកឡើងខាងលើ។

**អនុវត្តនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ** សំដៅលើការអនុវត្តនយោបាយដោយផ្អែកទៅលើគោលការណ៍សំខាន់ពីរ គឺ គោលការណ៍សាប់ស៊ីឌីយ៉ារីធី និងស្វ័យភាព។ វិមជ្ឈការ និងវិសហមជ្ឈការ ជាយន្តការពីរដែលមិនអាចផ្ដាច់ចេញពីគ្នាបាន វាបំពេញឲ្យគ្នាទៅវិញទៅមក។

**ក២. ការកែសម្រួលព្រំប្រទល់ ឈ្មោះរបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ**

គោលបំណងមួយទៀតរបស់ច្បាប់រៀបចំអង្គការ គឺការកែសម្រួលព្រំប្រទល់ ឈ្មោះរបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ ដើម្បីធ្វើយ៉ាងណាឲ្យមានការរៀបចំស្របទៅនឹងស្ថានភាពជាក់ស្ដែង សម្រាប់បើកផ្លូវដល់ការអភិវឌ្ឍ។ ក្នុងការកែ

សម្រួលឈ្មោះរបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ ចាំបាច់ត្រូវធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដាក់ស្តែងមាត្រា១៤៥ថ្មី និងមាត្រា១៤៦ថ្មី។

**ក៣. នីតិបុគ្គល**

ច្បាប់រៀបចំអង្គការ មានគោលបំណងធ្វើឲ្យរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ និងសង្កាត់ ក្លាយជានីតិបុគ្គល។ បច្ចុប្បន្ន រដ្ឋបាលថ្នាក់ក្រោមជាតិទាំងនេះ គឺជានីតិបុគ្គល ដែលតំណាងដោយក្រុមប្រឹក្សាដែលជាប់ឆ្នោតដោយសកល (ក្រុមប្រឹក្សាឃុំ/សង្កាត់) និងអសកល (ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។ នីតិបុគ្គល ធ្វើឲ្យក្រុមប្រឹក្សាទាំងនេះមានស្វ័យភាពទាំងរដ្ឋបាល ទាំងហិរញ្ញវត្ថុ ដើម្បីងាយស្រួលក្នុងការចាត់ចែងការងារនៅក្នុងដែនសមត្ថកិច្ចក្នុងមូលដ្ឋានរបស់ខ្លួន ដោយធ្វើយ៉ាងណាឲ្យឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាននោះ។

**ខ. រចនាសម្ព័ន្ធ និងតួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

ក្នុងរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ មានក្រុមប្រឹក្សា និងគណៈអភិបាល ដែលអង្គនីមួយៗមានលក្ខណៈ ដូចខាងក្រោម៖

**ខ១. ក្រុមប្រឹក្សា**

ក្រុមប្រឹក្សាជ្រើសតាំងដោយការបោះឆ្នោតអសកល (លើកលែងតែក្រុមប្រឹក្សាឃុំ/សង្កាត់ដែលបោះឆ្នោតដោយសកល)។ ក្នុងក្រុមប្រឹក្សាមាន គណៈកម្មាធិការមួយចំនួន ដូចជា៖

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
- គណៈកម្មាធិការលទ្ធកម្ម
- គណៈកម្មាធិការផ្សេងៗទៀតតាមការចាំបាច់។

**ខ២. គណៈអភិបាល**

គណៈអភិបាលរួមមាន អភិបាល ០១រូប និងអភិបាលរងមួយចំនួន។ អភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានតែងតាំងដោយរាជរដ្ឋាភិបាល ហើយមានអាណត្តិមិនលើសពី៤ឆ្នាំ។ ក្រៅពីនេះនៅមាននាយករដ្ឋបាលដែលជាប្រតិបត្តិករប្រចាំថ្ងៃក្នុងការងាររដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយមានទីចាត់ការ (សម្រាប់រដ្ឋបាលរាជធានី/ខេត្ត) ឬការិយាល័យ (សម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ) មួយចំនួនទៀតជាចំណុះ។

**ខ៣. តួនាទីក្រុមប្រឹក្សា**

ក្រុមប្រឹក្សាមានអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ។ ដីកាគឺជាវិធានខាងផ្លូវច្បាប់ដែលអនុម័តដោយក្រុមប្រឹក្សា។ ក្រុមប្រឹក្សាមានតួនាទីពិនិត្យ និងអនុម័តផែនការអភិវឌ្ឍ និងថវិការបស់ខ្លួន។

**ខ៤. តួនាទីគណៈអភិបាល**

គណៈអភិបាលមានតួនាទី សំខាន់ៗដូចខាងក្រោម៖

- ណែនាំ សម្របសម្រួល និងតម្រង់ទិសមន្ទីរ អង្គភាពនានាដែលធ្វើសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា
- ផ្តល់យោបល់ និងរាយការណ៍ជូនក្រុមប្រឹក្សា
- អនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា
- រៀបចំផែនការអភិវឌ្ឍ និងគម្រោងថវិកា ដើម្បីក្រុមប្រឹក្សាពិនិត្យ និងអនុម័ត
- ពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ អ្នកពាក់ព័ន្ធនានាអំពីបញ្ហាចាំបាច់។

**ខ៥. គណនេយ្យភាព**

ក្រុមប្រឹក្សាមានគណនេយ្យភាពចំពោះ

- ប្រជាពលរដ្ឋ
- រាជរដ្ឋាភិបាល

គណៈអភិបាលមានគណនេយ្យភាពចំពោះ

- រាជរដ្ឋាភិបាល
- ក្រុមប្រឹក្សា

**ខ៦. គណៈបញ្ជាការឯកភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

អភិបាលត្រូវធ្វើជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័ន ពាក់ព័ន្ធក្នុងការងារសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ ច្បាប់ និងសិទ្ធិមនុស្ស។ អភិបាលគឺជាប្រធានគណៈបញ្ជាការឯកភាព។

**គ. មុខងារ បុគ្គលិក និងធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

រដ្ឋបាលថ្នាក់ក្រោមជាតិមានមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើស។ មុខងារទាំងពីរប្រភេទនេះ អាចត្រូវបានផ្ទេរទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិដោយការប្រគល់ (ផ្តល់ទាំងភាពជាម្ចាស់) ឬការធ្វើប្រតិភូកម្ម (ថ្នាក់ជាតិរក្សាភាពជាម្ចាស់)។

ចំពោះបុគ្គលិករបស់ក្រុមប្រឹក្សា រួមមាន៖

- បុគ្គលិកតែងតាំងដោយក្រុមប្រឹក្សា
- បុគ្គលិកតែងតាំងឲ្យធ្វើការជាមួយក្រុមប្រឹក្សា
- បុគ្គលិលដែលត្រូវរៀបចំឡើងវិញ

រីឯសមាជិកក្រុមប្រឹក្សា មន្ត្រីនៃក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា ឬមន្ត្រីដទៃទៀត អនុវត្តភារកិច្ចពាក់ព័ន្ធនឹងសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ ច្បាប់ និងសិទ្ធិមនុស្ស គឺមិនរាប់បញ្ចូលជាបុគ្គលិករបស់ក្រុមប្រឹក្សាឡើយ។

ចំពោះធនធានរបស់ក្រុមប្រឹក្សា រួមមាន ថវិកា ចំណូល ដែលបានមកពីប្រភពមូលដ្ឋាន ប្រភពថ្នាក់ជាតិ និងប្រភពផ្សេងៗ និងធនធានមួយទៀត គឺទ្រព្យសម្បត្តិដែលរដ្ឋផ្ទេរឲ្យ ឬក្រុមប្រឹក្សារកបានដោយខ្លួនឯង។

**ឃ. គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** (គ.ជ.អ.ប.)

**ឃ១. រចនាសម្ព័ន្ធ**

គ.ជ.អ.ប. ជាស្ថាប័នអន្តរក្រសួង និងអន្តរវិស័យដែលមានសមាជិកមកពីក្រសួង/ស្ថាប័ន ពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលដែលមានរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាប្រធាន។ គ.ជ.អ.ប. មានអនុគណៈកម្មធិការយ៉ាងតិច ០៤ជាជំនួយការ គឺ អនុគណៈកម្មាធិការមុខងារ និងធនធាន អនុគណៈកម្មាធិការកិច្ចការសារពើពន្ធ និងហិរញ្ញវត្ថុ អនុគណៈកម្មាធិការបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអនុគណៈកម្មាធិការផែនការអភិវឌ្ឍថ្នាក់ក្រោមជាតិ។ ក្រៅពីនេះ គ.ជ.អ.ប. មានលេខាធិការដ្ឋានមួយដែលស្ថិតក្នុងក្រសួងមហាផ្ទៃ។

**ឃ២. តួនាទី ភារកិច្ច**

គ.ជ.អ.ប. មានតួនាទី និងភារកិច្ចសំខាន់ៗដូចខាងក្រោម៖

- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីពិនិត្យ កំណត់មុខងារ និងរៀបផ្ទេរមុខងារឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- ធានាថារដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាព សមត្ថភាព និងមធ្យោបាយសមស្រប ដើម្បីអនុវត្តមុខងារដែលត្រូវបានផ្ទេរ
- ធានាថាច្បាប់រៀបចំអង្គការត្រូវអនុវត្តដោយក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់

- ធានាថា ក្រសួង ស្ថាប័ន របស់រាជរដ្ឋាភិបាលនៅថ្នាក់ជាតិ បានធ្វើសមាហរណកម្ម ផែនការអភិវឌ្ឍ និងថវិកា របស់ខ្លួននៅថ្នាក់ក្រោមជាតិទៅក្នុងផែនការ និងថវិការបស់ក្រុមប្រឹក្សា
- ធានាថាគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីកំណែទម្រង់នានាមានសង្គតិភាពជាមួយច្បាប់រៀបចំអង្គការ
- ផ្តល់អនុសាសន៍ដោយផ្ទាល់ដល់រាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នណាមួយអំពីការតាក់តែង ឬធ្វើវិសោធនកម្ម ច្បាប់ ឬលិខិតបទដ្ឋាននានាដើម្បីឲ្យស្របច្បាប់រៀបចំអង្គការ
- ដោះស្រាយ ឬលើកសំណើសុំសេចក្តីសម្រេចពីរាជរដ្ឋាភិបាល លើបញ្ហាមិនចុះសម្រុងគ្នាដែលកើតមាន ទាក់ទងនឹងច្បាប់រៀបចំអង្គការ។

## ៥. បញ្ហាប្រឈម និងសេចក្តីសន្និដ្ឋាន

### ក. បញ្ហាប្រឈម

ក្នុងការអនុវត្តច្បាប់រៀបចំអង្គការសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា ជួបនូវបញ្ហាប្រឈមដូចខាងក្រោម៖

- ការកសាង និងការអភិវឌ្ឍសមត្ថភាពសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ នៅតែជាបញ្ហាចម្បង និងបន្ទាន់ ដែលទាមទារត្រូវមានផែនការយុទ្ធសាស្ត្រសមស្របទៅតាមដំណាក់កាលច្បាស់លាស់
- ការធ្វើវិមជ្ឈការ និងវិសហមជ្ឈការសារពើពន្ធ ទាមទារនូវការប្តេជ្ញាចិត្ត និងការផ្តល់ទំនុកចិត្តដើម្បីថ្នាក់ក្រោមជាតិអាចអនុវត្តបាននូវមុខងារ និងការទទួលខុសត្រូវដែលបានប្រគល់ ឬធ្វើប្រតិភូកម្មឲ្យ
- ការរៀបចំចងក្រងឧបករណ៍គតិយុត្តទាំងឡាយ ដើម្បីគាំទ្រការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ និងដើម្បីធានាការអនុវត្តច្បាប់គ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិឲ្យមានប្រសិទ្ធភាពនៅតែជាសំណូមពរបន្ទាន់ និងចាំបាច់។

### ខ. សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក វិមជ្ឈការ និងវិសហមជ្ឈការ គឺគ្រាន់តែជាមធ្យោបាយឆ្ពោះទៅកាន់គោលដៅនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ មានន័យថា ពុំមានពុម្ពគំរូណាមួយសម្រាប់វិមជ្ឈការ និងវិសហមជ្ឈការឡើយ គឺវិមជ្ឈការ និងវិសហមជ្ឈការ ត្រូវតែជាផលិតផលរបស់កម្ពុជា ដែលសំដៅទៅលើរបៀបដឹកនាំ និងគ្រប់គ្រងបែបកម្ពុជា ឆ្លើយតបទៅនឹងតម្រូវការ និងស្ថានភាពជាក់ស្តែងរបស់កម្ពុជា។ ការចាប់ផ្តើម និងការគាំទ្រនិរន្តរភាពនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ គឺជាដំណើរការកំណែទម្រង់មានលក្ខណៈស្មុគស្មាញ និងយូរអង្វែង ដែលប្រការនេះទាមទារនូវឆន្ទៈនយោបាយមោះមុត ការតស៊ូអត់ធ្មត់ និងការផ្លាស់ប្តូរផ្នត់គំនិតរបស់គ្រប់ថ្នាក់ គ្រប់ផ្នែក និងអ្នកពាក់ព័ន្ធទាំងអស់។

រៀបចំដោយ

សិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី៧ (ក្រុមទី៩)